01374483

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 05 / 01 / 2017
ម៉ោង (Time/Heure): 11:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

002/19-09-2007-ECCC/TC
**E1/481**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ អង្គារ ទី ១១ ខែ តុលា ឆ្នាំ ២០១៦

## សវនាការលើភស្តុតាង - ថ្ងៃ ៤៦២

រៀបចំដោយ៖ លោក **ឯម ហ៊ីយ** និង លោកស្រី Evelyn CAMPOS SANCHEZ

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា, ចៅក្រម Claudia FENZ |
| ចៅក្រមបំរុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី ៖ លោក ឯម ហ៊ីយ, លោកស្រី Evelyn CAMPOS SANCHEZ |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង លាង, លោក Nicholas KOUMJIAN |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អរុណ, លោក លីវ សុវណ្ណា |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSÉ |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក ពេជ អង្គ, លោក វ៉ែន |

| |
|---|
| ពៅ, លោក ហុង គឹមសួន , លោកស្រី ស៊ិន សុវ៉ន, លោក ឡោ ជុនធី |
| ដើមបណ្តឹង/សាក្សី/អ្នកជំនាញ៖ កញ្ញា LEVINE Peg (2-TCE-81) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី សួរ សុធ្ធារី |
| ផ្សេងៗ៖ លោក កែវ វ៉ាត, លោក ឡូញ ង៉ែត,កញ្ញា ស្រី ណាក់,លោកស្រី ពេជ ចរិយា, លោក វ៉ាត សូម៉ៅ, Ms. Elodie KANCEL |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦ | ចាប់ផ្តើមម៉ោង៖ ០៩.០១ | បញ្ចប់ម៉ោង៖ ១៦.០២ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.២០ | បញ្ចប់ម៉ោង៖ ១០.៣៩ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.៣៥ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤៥ | បញ្ចប់ម៉ោង៖ ១៥.០៣ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៤ ម៉ោង និង ២៩ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០១ | ០៩.០៣ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.03 | ០៩.04 |
| ការតាំងសំណួរទៅកាន់អ្នកជំនាញ LEVINE Peg (2-TCE-81) | មេធាវីការពារក្តី ខៀវ សំផន<br>អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា | ០៩.០ ៧<br>១០.០៥<br>១១.១៩<br>១៣.៣១ | ០៩.៥៩<br>១១.១៦<br>១១.៣៥<br>១៥.៥៩ |
| សេចក្តីសម្រេចផ្ទាល់មាត់លើសំណើផ្ទាល់មាត់របស់សហព្រះរាជអាជ្ញា សុំបន្ថែមពេលវេលាសម្រាប់ការតាំង សំណួរទៅកាន់អ្នកជំនាញ LEVINE Peg (2-TCE-81) | សហព្រះរាជអាជ្ញា<br>អង្គជំនុំជម្រះ | ០៩.៥៩<br>១១.១៩ | ១០.00<br>១១.១៩ |

| | | | |
|---|---|---|---|
| សេចក្ដីសម្រេចផ្ទាល់មាត់ស្ដីពីការទទួលយកឯកសារចំនួន ២ ដែលពាក់ព័ន្ធទៅនឹងការតាំងសំណួរទៅកាន់អ្នកជំនាញ LEVINE Peg (2-TCE-81) | អង្គជំនុំជម្រះ | ១០.០៣ | ១០.០៥ |
| សេចក្ដីសម្រេចផ្ទាល់មាត់ លើសំណើរបស់មេធាវីការពារក្ដី នួន ជា សុំឱ្យទទួលយកឯកសារថ្មី ជាឯកសារភស្ដុតាង ដោយអនុលោមតាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង (ឯកសារ E434 and E435) | អង្គជំនុំជម្រះ | ១៥.៥៩ | ១៦.០១ |

**<u>សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន ។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**<u>សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**<u>ការតាំងសំណួរទៅកាន់អ្នកជំនាញ</u>** <u>2-TCE-81</u>

អង្គជំនុំជម្រះ មេធាវីការពារក្ដី ខៀវ សំផន និងសហព្រះរាជអាជ្ញាបានតាំងសំណួរទៅកាន់អ្នកជំនាញ (2-TCE-81) ។

**<u>សេចក្ដីសម្រេចផ្ទាល់មាត់លើសំណើផ្ទាល់មាត់របស់សហព្រះរាជអាជ្ញា សុំពន្យាពេលវេលាសម្រាប់ការតាំងសំណួរទៅកាន់អ្នកជំនាញ</u>** <u>LEVINE Peg (2-TCE-81)</u>

សហព្រះរាជអាជ្ញាបានធ្វើសំណើផ្ទាល់មាត់ សុំបន្ថែមពេលវេលាសម្រាប់គ្រប់ភាគីទាំងអស់ ដើម្បីតាំងសំណួរទៅកាន់អ្នកជំនាញ LEVINE Peg (2-TCE-81) ដោយដកស្រង់នូវចំណុចសំខាន់ៗនៃសក្ខីកម្មរបស់

គាត់សម្រាប់ការសួរដេញដោល។ គ្មានការជំទាស់ចំពោះសំណើដែលបានលើកឡើងនេះទេ។ អង្គជំនុំជម្រះ បានទទួលសំណើរបស់សហព្រះរាជអាជ្ញា ហើយបានផ្តល់ពេលវេលាបន្ថែមមួយវគ្គសម្រាប់ភាគីទាំងអស់ ដើម្បីតាំងសំណួរទៅកាន់អ្នកជំនាញ LEVINE Peg (2-TCE-81)

<u>**សេចក្តីសម្រេចផ្ទាល់មាត់ ស្តីពីការទទួលយកឯកសារពាក់ព័ន្ធចំនួន ២ ដែលពាក់ព័ន្ធទៅនឹងការតាំងសំណួរទៅកាន់អ្នកជំនាញ** LEVINE Peg (2-TCE-81)</u>

អង្គជំនុំជម្រះមានបំណងទទួលយកឯកសារចំនួន ២ ដែលបានផ្តល់ឱ្យដោយអ្នកជំនាញ និង ដែលពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់គាត់ជាឯកសារភស្តុតាង ។ ភាគីទាំងអស់មិនមានការជំទាស់នោះទេ។ អង្គជំនុំជម្រះបានសម្រេចទទួលយកឯកសារចំនួន ២ ជាឯកសារភស្តុតាង (ឯកសារ E310679 and E3/10680)។

<u>**សេចក្តីសម្រេចផ្ទាល់មាត់លើសំណើរបស់មេធាវីការពារក្តី នួន ជា សុំឱ្យទទួលយកឯកសារជាឯកសារភស្តុតាង ដោយអនុលោមតាមវិធាន ៨៧ (៤) នៃ វិធានផ្ទៃក្នុង (ឯកសារ** E434 and E435</u>

អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចផ្ទាល់មាត់លើសំណើសុំដែលបានបង្ហាញដោយមេធាវីការពារក្តី នួន ជា កាលពីថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ចំពោះការទទួលយកឯកសារចំនួន ២០ ជាឯកសារភស្តុតាងថ្មី (សំណើដែលមានលេខឯកសារ E434 and E435) ។ ចំពោះឯកសារដែលមានលេខ E434 អង្គជំនុំជម្រះបានទទួលយកឯកសារដែលមានលេខ ១, ១១, និងលេខ ១២ ហើយបានបដិសេធ មិនទទួលយកឯកសារផ្សេងទៀត និងបានបដិសេធសំណើរបស់សហព្រះរាជអាជ្ញាដែលបានបង្ហាញនៅក្នុងឯកសារ E434/1 ដើម្បីកំណត់អត្តសញ្ញាណ និងកោះហៅបុគ្គលដែលត្រូវបានសម្ភាសន៍នៅក្នុងឯកសារលេខ ១៨ ។ ចំពោះឯកសារដែលមានលេខ E/435 អង្គជំនុំជម្រះបានទទួលយកឯកសារលេខ ៨ និង បដិសេធមិនទទួលយកឯកសារទាំងអស់ដែលនៅសេសសល់។

New E3s

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/1794 | D357.1.22 | 00894147-8, 00806226-9, 00806220-5, 00834033- | Authority 22: Peg Levine, A contextual Study into the Wedding and Births under the Khmer Rouges: The Ritual Revolution, thesis, Monash University | P | - | 00482602-00482610; 00482505; 00482607; | - |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | 42, 00806213-9/ 00482421-00482714/ 00809683-6, 00821550-3, 00822186-9 | Faculty of Arts, Asian Studies, (2007) | | | 00482528; 00482553; 00482664 | |
| E3/1067 6 | - | - 01330847-01330848, - | FINAL Submission of Transcripts for Court Review Peg Levine (23 September 2015) | P | - | 01330847-01330848 | - |
| E3/1067 7 | - | - 01334888-01335002, - | Booked by Peg Levine entitled "Love and Dread in Cambodia" | P | - | 01334892-01334898-01334899-01334902-01334947-01334950-01334951-01334952-01334959-01334985 | - |

**Reclassified**

## Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/420 2 | - | 00858214-00858410; 00757471-00757568; 00849349-00849484 | Book by GINA Chon and THET Sambath entitled "Behind the killing fields: a Khmer Rouge leader and one of his victims" | P | - | 00757496 | - |
| E3/16 | D213.21 | 00380221-00380560; 00498220-00498306; 00643822-00643913 | KHIEU Samphan, "Consideration on the history of Cambodia from Early stage to the Period of Democratic Kampuchea | P | 00380467 | 00498284 | 00643891 |
| E3/681 | D56 | 00651245-00651247; 00122194-00122195; 00630693-00630694 | Media Article by Henry KAMM entitled "Pol Pot" Aide Calls for World Support" in the New York Times dated 1 December 1980 | P | - | 00122194 | 00630694 |
| E3/775 | D267/3.36 | 00407096-00407108; 00417940-00417947; 00593926- | Global Vision: Revolution and non-revolution toward family building issue | P | 00407100 | 00417943 | 00593930 |

01374488



**ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៤)
- សេចក្ដីសម្រេចផ្ទាល់មាត់ ស្ដីពីការទទួលយកឯកសារចំនួន ២ ដែលពាក់ព័ន្ធទៅនឹងការតាំងសំណួរទៅកាន់អ្នកជំនាញ 2-TCE-81 (E3/10679 and E3/10680) (១០.០៣).
- សេចក្ដីសម្រេចផ្ទាល់មាត់ លើសំណើផ្ទាល់មាត់របស់សហព្រះរាជអាជ្ញា សុំពន្យាពេលវេលាសម្រាប់ការតាំងសំណួរទៅកាន់អ្នកជំនាញ 2-TCE-81 ។
- សេចក្ដីសម្រេចផ្ទាល់មាត់ ស្ដីពីការទទួលយកឯកសារ ជាឯកសារភ័ស្តុតាងថ្មី: ចំពោះឯកសារដែលមានលេខ E434 អង្គជំនុំជម្រះ បានទទួលយកឯកសារដែលមានលេខ ១, ១១, និងលេខ ១២ ហើយបានបដិសេធមិនទទួលយកឯកសារផ្សេងទៀត ។ ចំពោះឯកសារដែលមានលេខ E/435 អង្គជំនុំជម្រះ បានទទួលយកឯកសារលេខ ៨ ហើយបានបដិសេធមិនទទួលយកឯកសារផ្សេងទៀត ។ (១៦.០១)
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ៩.00 ព្រឹក នៅថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ។ (១៦.០២)

**កាលវេលាសវនាការបន្ត**

សវនាការនឹងបន្តទៅថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ចាប់ផ្ដើមពីម៉ោង ០៩.00 ព្រឹក។

ភ្នំពេញ ថ្ងៃទី ១១ ... ២០១៦

ក្រឡាបញ្ជី ... ក្រឡាបញ្ជី

លោក ឯម ហ៊ាង ... លោកស្រី Evelyn CAMPOS SANCHEZ